**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥៧៨ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៨

# ប្រកាស
# ស្តីពី
# ការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

### ប្រការ ១.-

ទំនិញនាំចូលទាំងឡាយ អាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយឱ្យនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិកបាន ប្រសិនបើក្នុងពេលនាំចូលអាចត្រូវបានបង្ហាញថា ទំនិញទាំងនោះនឹងត្រូវនាំចេញទៅវិញ ។

ទំនិញនាំចូលបណ្តោះអាសន្នដូចនេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគយ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌផ្សេងៗតាមរបបប្រវេសន៍កាលិក ត្រូវបានបំពេញរួចរាល់ស្របតាមបញ្ញត្តិមាត្រា ១៥ នៃច្បាប់ស្តីពីគយ ។

**ប្រការ ២.-**

ប្រវេសន៍កាលិក គឺជានីតិវិធីគយ ដែលអាចអនុញ្ញាតឱ្យទំនិញនាំចូលបានក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌរួចផុតពីការបង់ពន្ធ និងអាករទាំងស្រុង ឬភាគខ្លះ ។ ទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនធ្វើការកែច្នៃ ឬផ្លាស់ប្តូរ លើកលែងតែការរលស់ជាធម្មតាតាមការប្រើប្រាស់ ។

**ប្រការ ៣.-**

ការនាំចូលទំនិញក្រោមរបបប្រវេសន៍កាលិក ស្របតាមបញ្ញត្តិនៃប្រកាសនេះ អាចត្រូវបានអនុញ្ញាត ចំពោះករណីដូចខាងក្រោម :

១. ទំនិញសម្រាប់ដាក់តាំងបង្ហាញ ឬប្រើប្រាស់ក្នុងពិធីតាំងពិព័រណ៍ កិច្ចប្រជុំ ឬព្រឹត្តិការណ៍ប្រហាក់ប្រហែល ដែលមានបរិមាណសមស្រប ។ ទំនិញទាំងនេះពុំត្រូវបានអនុញ្ញាតឱ្យខ្ចី កាត់កង ឬយកចេញពីទីកន្លែងនៃព្រឹត្តិការណ៍ដូចខាងលើទេ ។ ទំនិញទាំងនេះរួមមាន :

- ទំនិញសម្រាប់បង្ហាញ ឬតាំងបង្ហាញ
- ទំនិញចាំបាច់សម្រាប់ការតាំងបង្ហាញនូវគ្រឿងម៉ាស៊ីន ឬបរិក្ខារបរទេស
- សម្ភារៈសំណង់ និងតុបតែងលម្អទីកន្លែងតាំងបង្ហាញ
- សម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្ម និងសម្រាប់បង្ហាញទំនិញបរទេសដូចជាខ្សែអាត់ រូបភាព សម្លេង និងឯកសារផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងទៀត
- បរិក្ខារផ្សេងទៀតរួមមាន បរិក្ខារបកប្រែ ឧបករណ៍ថត និងហ្វីលដែលមានលក្ខណៈវប្បធម៌ ឬវិទ្យាសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រជុំអន្តរជាតិនានា ។

២. បរិក្ខារវិជ្ជាជីវៈចាំបាច់សម្រាប់អ្នកបច្ចេកទេស ឬបុគ្គលវិជ្ជាជីវៈផ្សេងៗដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញការកិច្ច ឬមុខរបរឯកទេស ដោយមិនរាប់បញ្ចូលនូវបណ្តាគ្រឿងម៉ាស៊ីន គ្រឿងចក្រ និងបរិក្ខារឯកទេស សម្រាប់ការប្រើប្រាស់ក្នុងវិស័យកម្មន្តសាលឧស្សាហកម្ម ការវេចខ្ចប់ទំនិញ អាជីវកម្មធនធានធម្មជាតិ ការសាងសង់ ឬការជួសជុលអាគារ ការដាំដើ ឬគម្រោងប្រហាក់ប្រហែលនានាដែលនឹងត្រូវអនុវត្តតាមបញ្ញត្តិប្រការ ១០ នៃប្រកាសនេះ ។ ទំនិញទាំងនេះរួមមាន :

ក. បរិក្ខារដែលប្រើប្រាស់ដោយអ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជា:

- កុំព្យូទ័រ និងផ្នែកទន់របស់វា ទូរស័ព្ទ និងម៉ាស៊ីនទូរសារ ម៉ាស៊ីនថត ម៉ាស៊ីនថតសម្លេង រូប និងម៉ាស៊ីនបញ្ចាំងពន្លឺ

- បរិក្ខារបញ្ជូនសម្លេង ដោយរាប់បញ្ចូលទាំងឧបករណ៍ទទួល-បញ្ជូន

- បរិក្ខារផ្សព្វផ្សាយទូរទស្សន៍ដោយរាប់បញ្ចូលទាំងម៉ាស៊ីនថតឧបករណ៍បញ្ជូន ឧបករណ៍ទំនាក់ទំនង បរិក្ខារបោះពុម្ព បរិក្ខារតន្ត្រី ព្រមទាំងសម្ភារៈ និងសម្លៀកបំពាក់សម្រាប់សម្តែង

- យានយន្តឯកទេសសម្រាប់ការប្រើប្រាស់ជាពិសេស ដូចជា យានយន្តថតទូរទស្សន៍ចល័តជាដើម ។

ខ. បរិក្ខារភាពយន្ត រួមមាន ម៉ាស៊ីនថត បរិក្ខារបញ្ចាំងភ្លើង ឧបករណ៍ថតសម្លេង និងឧបករណ៍ពាក់ព័ន្ធផ្សេងទៀតព្រមទាំងយានយន្តពិសេសសម្រាប់សំណូមពរនេះ ។

គ. បរិក្ខារផ្សេងទៀតសម្រាប់ការប្រើប្រាស់របស់អ្នកបច្ចេកទេស ឬធុរជនវិជ្ជាជីវៈដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញភារកិច្ចដោយខ្សែករបស់ខ្លួនដែលអាចរួមមាន :

- បរិក្ខារឬឧបករណ៍សម្រាប់ដំឡើងបំបែក សាកល្បង ថែទាំ ឬជួសជុលគ្រឿងម៉ាស៊ីន ពាងចក្រ ឬមធ្យោបាយដឹកជញ្ជូន

- បរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់ធុរជនដូចជាកុំព្យូទ័រនិងទំនិញគ្រឿងអេឡិត្រូនិចផ្សេងៗ

- បរិក្ខារ ឬឧបករណ៍សម្រាប់ការអង្កេត ការវាស់ស្ទង់ ឬភូគព្ភសាស្ត្រ

- បរិក្ខារសម្រាប់ប្រើប្រាស់របស់អ្នកជំនាញការខាងផ្នែកប្រឆាំងការបំពុលបរិស្ថាន សម្រាប់បុរាណវិទូ ភូមិវិទូ អ្នកបរិស្ថាន អ្នកជំនាញការសត្វ និងរុក្ខជាតិ និងអ្នកវិទ្យាសាស្ត្រផ្សេងទៀត

- បរិក្ខារសម្រាប់វេជ្ជបណ្ឌិត គ្រូពេទ្យវះកាត់ ឬមនុស្ស ឬធ្មេញជាដើម

- បរិក្ខារចាំបាច់សម្រាប់ក្រុមសិល្បៈទស្សនីយភាព ក្រុមតន្ត្រី ដែលរួមមាន ឧបករណ៍តន្ត្រី និងបរិក្ខារពាក់ព័ន្ធដូចជា អំភ្លី ឧបករណ៍បំពងសម្លេង ឧបករណ៍តុបតែងឆាកជាដើម

- បរិក្ខារសម្រាប់ថតរូប

- យានយន្តឯកទេសសម្រាប់សំណូមពរខាងលើ ។

៣. កុងតេន័រ ប៉ាឡែត កញ្ចប់ គម្រូទំនិញ និងទំនិញនាំចូលផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម តែពុំមែនជាផ្នែកនៃប្រតិបត្តិការពាណិជ្ជកម្មនៅពេលដែលត្រូវបានលក់ ឬទិញ ។ ទំនិញទាំងនេះរួមមាន :

- ស្រោម សម្បកវេចខ្ចប់ សម្រាប់ការប្រើប្រាស់ច្រើនដង
- កុងតេន័រ និងគ្រឿងបន្សំ ព្រមទាំងបំណែក ដែលអាចប្រើប្រាស់ឡើងវិញបានសម្រាប់ការដឹកជញ្ជូន ហើយនឹងត្រូវនាំចេញទៅវិញ
- ប៉ាឡែតដែលអាចប្រើច្រើនដង
- គម្រូទំនិញគ្មានតម្លៃពាណិជ្ជកម្ម
- ហ្វីលផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ការបង្ហាញទាក់ទាញអតិថិជន
- ទំនិញផ្សេងទៀតសម្រាប់សាកល្បង ត្រួតពិនិត្យ ពិសោធន៍ ឬបង្ហាញ ដូចជា ហ្វីលលាងរួច និងព័ត៌មាននាំចូលផ្សេងទៀតសម្រាប់មើលមុននឹងប្រើប្រាស់ក្នុងបំណងពាណិជ្ជកម្ម សម្រាប់ថតសម្លេង ផលិតបន្ថែម ទិន្នន័យដែលឥតគិតថ្លៃសម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធកុំព្យូទ័រ និងមុខទំនិញផ្សេងទៀតដែលតាមធម្មជាតិរបស់វា សម្រាប់ប្រើប្រាស់តែការផ្សព្វផ្សាយជាពិសេសប៉ុណ្ណោះ ។

៤. ទំនិញនាំចូលសម្រាប់តែសំណូមពរនៃការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ រាប់បញ្ចូលទាំងបំណែកនៃបរិក្ខារវិទ្យាសាស្ត្រ និងសម្ភារៈអប់រំដែលទទួលបានការអនុញ្ញាតឱ្យនាំចូលតាមរបបប្រវេសន៍កាលិក ។

៥. ទំនិញនាំចូលសម្រាប់វិស័យកីឡាដែលប្រើប្រាស់ដោយអ្នកទេសចរ កីឡាករ អ្នកដំណើរសម្រាប់ការប្រកួតប្រជែងការបង្ហាញ ឬការហ្វឹកហាត់ក្នុងដែនគយ ។ ទំនិញទាំងនេះរួមមាន បរិក្ខារកីឡា សម្លៀកបំពាក់កីឡា បរិក្ខារកីឡាក្នុងទឹក ( ទូកប្រភេទផ្សេងៗ ) យានយន្ត និងគ្រឿងបំពាក់ព្រមទាំងបរិក្ខារផ្សេងទៀតៗ ។

៦. សម្ភារៈផ្សព្វផ្សាយទេសចរ សម្រាប់ទាក់ទាញការទស្សនាប្រទេសផ្សេងទៀតៗ

៧. ទំនិញនាំចូលដោយអ្នកដំណើរឆ្លងកាត់ព្រំដែនសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនៗ

៨. ទំនិញនាំចូលសម្រាប់គោលបំណងមនុស្សធម៌ រាប់បញ្ចូលទាំង បរិក្ខារមន្ទីរពិសោធន៍ មន្ទីរវះកាត់ និងទំនិញជំនួយសង្គ្រោះជនរងគ្រោះដោយគ្រោះធម្មជាតិ និងមហន្តរាយប្រហាក់ប្រហែល ។

៩. មធ្យោបាយដឹកជញ្ជូនមនុស្ស និងទំនិញ សម្រាប់គោលបំណងពាណិជ្ជកម្ម ដូចជា នាវា អាកាសយាន យានយន្តផ្លូវគោក ឬផ្លូវដែកដែលប្រើប្រាស់ក្នុងចរាចរដឹកជញ្ជូនជាអន្តរជាតិ រាប់បញ្ចូលទាំងគ្រឿងបន្លាស់ គ្រឿងបន្សំ និងបរិក្ខារផ្សេងៗ ទោះបីជាមិនយកកម្រៃក្តី ។ របបប្រវេសន៍កាលិកមធ្យោបាយដឹកជញ្ជូនដូចនេះ ត្រូវអនុលោមតាមកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួម ។

ដើម្បីទទួលបាននូវរបបប្រវេសន៍កាលិកដូចមានចែងក្នុងបញ្ញត្តិចំណុចទី ៤

ចំណុចទី ៤ និងចំណុចទី ៦ នៃប្រការនេះ ទំនិញទាំងនេះត្រូវតែជាកម្មសិទ្ធិរបស់បុគ្គលនៅក្រៅដែនគយ និងត្រូវនាំចូលក្នុងបរិមាណសមស្របសម្រាប់តែការប្រើប្រាស់តាមសំណូមពរនីមួយៗប៉ុណ្ណោះ ។

**ប្រការ ៤.-**

មុនពេលនាំចូល បុគ្គលដែលមានបំណងនាំចូលទំនិញតាមរបបប្រវេសន៍កាលិក ត្រូវដាក់ពាក្យសុំការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។ ពាក្យសុំត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវប្រភេទទំនិញ បរិមាណ តម្លៃ គោលបំណងនៃការនាំទំនិញចូល អត្តសញ្ញាណរបស់ម្ចាស់ទំនិញ រយៈពេលនៃការទទួលបានរបបប្រវេសន៍កាលិក និងកាលបរិច្ឆេទនៃការនាំចេញទៅវិញ ។

រដ្ឋបាលគយត្រូវលើកលែងនូវការតម្រូវនេះ ចំពោះទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិជាធរមាន ដូចជា ការនាំចូលម្តងម្កាលដោយអ្នកដំណើរសម្រាប់តម្រូវការផ្ទាល់ខ្លួន និងទំនិញនាំចូលដោយប្រជាពលរដ្ឋតំបន់ព្រំដែនជាដើម ។ ការអនុគ្រោះដូចនេះក៏អាចអនុវត្តផងដែរចំពោះទំនិញទំនិញដែលមានតម្លៃទាប ឬទំនិញដែលមានហានិភ័យទាបដូចជាសម្បកកុងតេន័រ ឬប៉ាឡែតជាដើម ។

**ប្រការ ៥.-**

ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិក ជាកម្មវត្ថុនៃការតម្កល់ប្រតិវេទន៍គយ ។ រដ្ឋបាលគយអាចទទួលយកបាននូវការប្រកាសដោយផ្ទាល់មាត់ចំពោះទំនិញនាំចូលគ្មានលក្ខណៈពាណិជ្ជកម្មស្របតាមបទប្បញ្ញត្តិជាធរមាន ដូចជា ការនាំចូលម្តងម្កាលដោយអ្នកដំណើរសម្រាប់តម្រូវការផ្ទាល់ខ្លួន ទំនិញនាំចូលដោយប្រជាពលរដ្ឋតំបន់ព្រំដែន ទំនិញដែលមានតម្លៃទាប ឬទំនិញដែលមានហានិភ័យទាបដូចជាសម្បកកុងតេន័រ ឬប៉ាឡែតជាដើម ។

**ប្រការ ៦.-**

រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់និមុត្តិធានា ដើម្បីធានានូវពន្ធ និងអាករចំពោះទំនិញនាំចូលក្រោមរបបប្រវេសន៍កាលិក ។ ចំនួនទឹកប្រាក់និមុត្តិធានាដែលតម្រូវនឹងមិនត្រូវឱ្យលើសពីទឹកប្រាក់ពន្ធ និងអាករដែលទំនិញត្រូវជាប់ ។ ដោយផ្អែកលើការវាយតម្លៃហានិភ័យ រដ្ឋបាលគយ អាចអនុញ្ញាតឱ្យតម្កល់ទឹកប្រាក់និមុត្តិធានាទាបជាងទឹកប្រាក់ពន្ធ និងអាករដែលទំនិញត្រូវជាប់ ។

ការតម្រូវឱ្យតម្កល់និមុត្តិធានាអាចត្រូវបានលើកលែងចំពោះប្រភេទទំនិញដូចខាងក្រោម :

- ទំនិញនាំចូលម្តងម្កាលដោយអ្នកដំណើរសម្រាប់តម្រូវការផ្ទាល់ខ្លួន
- ទំនិញនាំចូលដោយប្រជាពលរដ្ឋតំបន់ព្រំដែន
- ទំនិញដែលមានតម្លៃទាប ទំនិញដែលមានហានិភ័យទាប ដូចជា សម្បកកុងតេន័រ ប៉ាឡែត ឬសម្បកវេចខ្ចប់ និងទំនិញគម្រូដែលគ្មានតម្លៃពាណិជកម្មជាដើម
- ទំនិញនាំចូលសម្រាប់គោលបំណងមនុស្សធម៌
- ករណីលើកលែងដទៃទៀត តាមការកំណត់របស់ នាយកទីចាត់ការគយ និងរដ្ឋាករ ។

ការតម្កល់និមុត្តិធានាត្រូវធ្វើឡើងស្របតាមបញ្ញត្តិនៃប្រកាសស្តីពីនិមុត្តិធានា និងបញ្ញត្តិមាត្រា ៤១ នៃច្បាប់ស្តីពីគយ ។

និមុត្តិធានាដែលតម្កល់សម្រាប់ការនាំចូលបណ្តោះអាសន្ន នឹងត្រូវលុបចោល ឬបង្វិលសងវិញ នៅពេលដែលមានការបញ្ជាក់ថា ទំនិញត្រូវបាននាំចេញទៅវិញ ។ នាយកទីចាត់ការគយ និងរដ្ឋាករអាចដោះបន្ទុកនិមុត្តិធានាដែលបានធានាចំពោះការនាំចេញទៅវិញ នៅក្នុងករណីដែលមានការជូនសំអាងថាទំនិញត្រូវបាននាំចេញទៅវិញ ។

រដ្ឋបាលគយអាចកិបសៀលគយ បិទត្រាគយ បោះត្រាចំណាំ ឬប្រើប្រាស់វិធានការផ្សេងទៀតលើការនាំចូលទំនិញដែលមានហានិភ័យខ្ពស់តាមរបបប្រវេសន៍កាលិកដើម្បីអាចកំណត់អត្តសញ្ញាណទំនិញទាំងនេះបាន ។

**ប្រការ ៧.-**

ទំនិញនាំចូលបណ្តោះអាសន្នក្រោមរបបប្រវេសន៍កាលិក ត្រូវនាំចេញទៅវិញក្នុងរយៈពេលមួយឆ្នាំ គិតពីថ្ងៃដែលទំនិញត្រូវបាននាំចូល ។ រយៈពេលកំណត់នេះអាចត្រូវបានពន្យារដោយរដ្ឋបាលគយប្រសិនបើមានសំណើសុំជាលាយលក្ខណ៍អក្សរមុនពេលផុតរយៈពេលកំណត់ និងដោយមានបញ្ជាក់ហេតុផលនៃសំណើនេះ ។

**ប្រការ ៨.-**

ប្រសិនបើមានការស្នើសុំ រដ្ឋបាលគយអាចអនុញ្ញាតឱ្យផ្ទេរនូវផលប្រយោជន៍នៃរបបប្រវេសន៍កាលិកទៅបុគ្គលណាមួយផ្សេងទៀត ក្នុងករណីដែលបុគ្គលនេះបំពេញគ្រប់ការតម្រូវ និងយល់ព្រមទទួលនូវលក្ខខណ្ឌទាំងឡាយដែលកើតមានឡើងក្រោមរបបប្រវេសន៍កាលិកមុនពេលស្នើសុំផ្ទេរនេះ ។

**ប្រការ ៩.-**

ការនាំចូលទំនិញតាមរបបប្រវេសន៍កាលិកអាចត្រូវបានបញ្ចប់តាមរយៈ

ការនាំចេញទៅវិញ ឬការដាក់ទំនិញនេះនៅក្រោមរបបគយផ្សេងទៀតដូចជា របបគយឆ្លងកាត់ កណ្តាគារគយមានដែនកំណត់ តំបន់រួចពន្ធ គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្រោមបញ្ញត្តិនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឬការដាក់ឱ្យប្រើប្រាស់ក្នុងប្រទេសដោយតម្រូវឱ្យបង់ពន្ធ និងអាករជាដើម ។ ប្រតិវេទន៍គយសម្រាប់ការបញ្ចប់របបប្រវេសន៍កាលិក ត្រូវចុះយោងនូវប្រតិវេទន៍នាំចូលពាក់ព័ន្ធ ។ និមុត្តិធានាទាំងឡាយនឹងត្រូវបានប្រគល់ជូនម្ចាស់ទំនិញវិញក្រោយពេលដែលកាតព្វកិច្ចនានាត្រូវបានបំពេញរួច ។

អ្នកនាំចូលទំនិញតាមរបបប្រវេសន៍កាលិក ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចមានចែងនៅក្នុងប្រកាសនេះ រួមទាំងលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាតដែលចេញដោយរដ្ឋបាលគយ ។ ក្នុងករណីមានការរំលោភណាមួយលើបញ្ញត្តិនៃប្រកាសនេះ ឬនិមុត្តិធានាមិនត្រូវបានដោះបន្ទុកទៅតាមរយៈពេលកំណត់ អ្នកនាំចូលទំនិញតាមរបបប្រវេសន៍កាលិកត្រូវទទួលរងនូវទោសទណ្ឌស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ១០.-**

បណ្តាគ្រឿងម៉ាស៊ីន គ្រឿងចក្រ និងបរិក្ខារឯកទេស សម្រាប់ការប្រើប្រាស់ក្នុងវិស័យកម្មន្តសាលឧស្សាហកម្ម ការវេចខ្ចប់ទំនិញ អាជីវកម្មធនធានធម្មជាតិ ការសាងសង់ ឬការជួសជុលអាគារ ការដាំដើ ឬគម្រោងប្រហាក់ប្រហែលនានា អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឱ្យនាំចូលបណ្តោះអាសន្នក្រោមរបបប្រវេសន៍កាលិកសម្រាប់រយៈពេលកំណត់មួយ ។ ពាក្យស្នើសុំនាំចូលតាមរបបប្រវេសន៍កាលិកនូវទំនិញទាំងនេះ ត្រូវដាក់ជូនរដ្ឋបាលស្របតាមបញ្ញត្តិប្រកា ៤ នៃប្រកាសនេះ ។

កាតព្វកិច្ចពន្ធ និងអាករ លើទំនិញនាំចូលបណ្តោះអាសន្នដូចនេះ ត្រូវជាប់តាមអត្រាបន្ថយស្មើនឹង ម្ភៃ (២០) ភាគរយ នៃកាតព្វកិច្ចពន្ធ និងអាករដែលត្រូវជាប់តាមតារាងពន្ធគយជាធរមានសម្រាប់រយៈពេលមួយឆ្នាំ ។ កាតព្វកិច្ចពន្ធ និងអាករដែលជាប់ត្រូវបង់ជាបន្ទាន់ក្រោយពេលដែលពាក្យសុំនាំចូលទំនិញតាមរបបប្រវេសន៍កាលិកនេះ ត្រូវបានយល់ព្រម ។

ក្នុងករណីដែលរយៈពេលកំណត់នៃរបបប្រវេសន៍កាលិកដូចនេះតិចជាងមួយឆ្នាំ កាតព្វកិច្ចពន្ធ និងអាករដែលត្រូវជាប់ត្រូវគិតតាមខែនីមួយៗតាមអត្រាបន្ថយស្មើនឹង ពីរ (២) ភាគរយនៃប្រាក់ពន្ធ និងអាករសរុបលើទំនិញទាំងនេះ ។

ការស្នើសុំពន្យាររយៈពេលកំណត់ ចំពោះការនាំចូលបណ្តោះអាសន្នតាមរបបប្រវេសន៍កាលិក ត្រូវធ្វើឡើងស្របតាមបញ្ញត្តិប្រការ ៧ នៃប្រកាសនេះ ។ កាតព្វកិច្ចពន្ធ

និងអាករដែលជាប់ត្រូវបង់ជាបន្ទាន់ ក្រោយពេលដែលសំណើសុំពន្យាររយៈពេលកំណត់ត្រូវបានយល់ព្រម ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ១២
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ